ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០២៥.០០៥ ប្រក.ក

# ប្រកាស
# ស្ដីពី
# ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី វិសោធនកម្មមាត្រា១៤និងមាត្រា៥៧នៃច្បាប់ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រាក់បម្រុងកាតព្វកិច្ចទាំងប្រាក់រៀល និងរូបិយប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ក្នុងរយៈពេលតម្កល់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងសន្ទនីយភាពប្រកបដោយសុវត្ថិភាព និងភាពរឹងមាំ។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **រយៈពេលមូលដ្ឋាន** ជារយៈពេល ១៤ ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវយកប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ មកកំណត់ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា។
- **រយៈពេលតម្កល់** ជារយៈពេល ១៤ ថ្ងៃប្រតិទិនបន្តបន្ទាប់ ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មបម្រុងដើម្បីអនុលោមតាមប្រកាសនេះ។
- **មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ** ជាចំនួនសរុបនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗក្នុងរយៈពេលមូលដ្ឋានចែកនឹង ១៤។ ផលចែកដែលជាមធ្យមភាគប្រចាំថ្ងៃ ត្រូវប្រើសម្រាប់កំណត់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់។ មធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ ត្រូវគណនាដោយឡែកពីគ្នា សម្រាប់ប្រាក់រៀល និងរូបិយប័ណ្ណ ស្របតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។
- **អត្រាប្រាក់បម្រុងកាតព្វកិច្ច** ជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជាអនុវត្តចំពោះចំនួនមធ្យមនៃប្រាក់បញ្ញើនិងប្រាក់កម្ចី សម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកជាមធ្យមក្នុងរយៈពេលតម្កល់។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់សម្រាប់ប្រាក់រៀល និងសម្រាប់រូបិយប័ណ្ណ នៅក្នុងបទប្បញ្ញត្តិដោយឡែក។
- **មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់** ជាចំនួនប្រាក់បម្រុងដែលត្រូវរក្សាទុកក្នុងទម្រង់ជាទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជាដើម្បីឱ្យស្របតាមការកំណត់របស់បទប្បញ្ញត្តិនេះ។ ចំនួនប្រាក់បម្រុងនេះ ត្រូវបានគណនាដោយ បូកចំនួនទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ១៤ ថ្ងៃ ចែកនឹង ១៤។ មធ្យមភាគនៃការរក្សាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ត្រូវបានគណនាដោយឡែកពីគ្នា ចំពោះប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ ស្របតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។
- **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា** ជាផលគុណរវាងអត្រាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមួយមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗ។ ចំនួននេះត្រូវបានគណនានៅមុនរយៈពេលត្រូវតម្កល់ ហើយត្រូវរាយការណ៍មកធនាគារជាតិនៃកម្ពុជាទៅតាមកាលកំណត់។ ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាត្រូវបានគណនាសាជាថ្មី និងដោយឡែកពីគ្នារៀងរាល់ ១៤ថ្ងៃ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ជាប្រាក់រៀល និងជារូបិយប័ណ្ណ។
- **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** ជាចំនួនយ៉ាងតិច ៣០% នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល និងយ៉ាងតិច ៨០% នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណផ្សេងៗ ដែលត្រូវតម្កល់ជារៀងរាល់ថ្ងៃ ក្នុងរយៈពេលតម្កល់នៅក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចរបស់គ្រឹះស្ថាននីមួយៗដែលមាននៅធនាគារជាតិនៃកម្ពុជា។

- **ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់** ជាចំនួនទ្រព្យសកម្មបម្រុងដែលត្រូវរក្សាក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់រកមធ្យមភាគនៃទ្រព្យសកម្មអប្បបរមា និងដើម្បីឱ្យស្របទៅតាមការកំណត់របស់បទប្បញ្ញត្តិជាធរមាន។

  ទ្រព្យសកម្មដែលអាចទទួលយកបានត្រូវតម្កល់ រួមមានដូចជា៖

  - ប្រាក់រៀល៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីផាត់ទាត់ជាប្រាក់រៀលក្នុងរយៈពេលតម្កល់ ១៤ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា និង
  - រូបិយប័ណ្ណ៖ សមតុល្យគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ក្នុងរយៈពេលតម្កល់ ១៤ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ២
## ប្រាក់បម្រុងកាតព្វកិច្ច

### ប្រការ ៤.-

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍អនុវត្តគោលនយោបាយរូបិយវត្ថុផង និងជាកាតព្វកិច្ចត្រួតពិនិត្យគ្រឹះស្ថានផង។ អត្រាប្រាក់បម្រុងកាតព្វកិច្ចអាចមានការផ្លាស់ប្តូរទៅតាមគោលដៅអនុវត្តគោលនយោបាយរូបិយវត្ថុ និងកាលៈទេសៈសេដ្ឋកិច្ចសកល។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិដោយឡែក។

### ប្រការ ៥.-

គ្រឹះស្ថានត្រូវបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យសន្ទនីយភាពប្រុងប្រយ័ត្ននិងសមស្របដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានកំណត់ក្នុងប្រកាសនេះ។

## ជំពូកទី ៣
## ទ្រព្យសកម្មអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

### ប្រការ ៦.-

គ្រឹះស្ថានត្រូវរក្សាទុកជាមធ្យមនូវសមតុល្យគ្រប់គ្រាន់នៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា។

### ប្រការ ៧.-

សាច់ប្រាក់ក្នុងដៃ មិនត្រូវចាត់ទុកជាទ្រព្យសកម្មដែលអាចទទួលយកបាន ដើម្បីតម្កល់ជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាឡើយ។

ទ្រព្យសកម្មដែលអាចទទួលយកបានសម្រាប់តម្កល់ជាប្រាក់បម្រុងកាតព្វកិច្ច ត្រូវបានកំណត់ដូចខាងក្រោម៖

- សមតុល្យប្រចាំថ្ងៃក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច និងគណនីផាត់ទាត់ជាប្រាក់រៀលរបស់គ្រឹះស្ថាន ដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា និង
- សមតុល្យប្រចាំថ្ងៃក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណរបស់គ្រឹះស្ថានដែលរក្សាទុកនៅធនាគារជាតិនៃកម្ពុជា។

៤

## ជំពូកទី ៤
## រយៈពេលមូលដ្ឋាន និងរយៈពេលតម្កល់

**ប្រការ ៨.-**

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្អែកលើរយៈពេលពីរផ្សេងគ្នា ដែលមានរយៈពេល ១៤ ថ្ងៃប្រតិទិន ជាបន្តបន្ទាប់ គឺ "រយៈពេលមូលដ្ឋាន" និង "រយៈពេលតម្កល់"។

**ប្រការ ៩.-**

រយៈពេលមូលដ្ឋាន ជារយៈពេល ១៤ ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានគណនាមធ្យមភាគប្រចាំថ្ងៃនៃប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ដើម្បីកំណត់ប្រាក់បម្រុងកាតព្វកិច្ចមធ្យមប្រចាំថ្ងៃ និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ សម្រាប់រាយការណ៍មកធនាគារជាតិនៃកម្ពុជា។ ចំនួនប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមដែលត្រូវរក្សាទុកក្នុងរយៈពេលតម្កល់ ត្រូវគណនាដោយយកមធ្យមភាគនៃប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗក្នុងរយៈពេលមូលដ្ឋាន គុណនឹងអត្រាប្រាក់បម្រុងកាតព្វកិច្ចជាធរមាន។

**ប្រការ ១០.-**

រយៈពេលតម្កល់ចាប់ផ្តើមនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន។

រយៈពេលតម្កល់មានរយៈពេល ១៤ ថ្ងៃប្រតិទិន ដែលគ្រឹះស្ថានត្រូវរក្សាទ្រព្យសកម្មដែលអាចទទួលយកបានស្របតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាមធ្យមនៅគ្រប់ ១៤ ថ្ងៃនៃរយៈពេលមូលដ្ឋាន។

## ជំពូកទី ៥
## មធ្យមភាគនៃទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់

**ប្រការ ១១.-**

ប្រព័ន្ធប្រាក់បម្រុងកាតព្វកិច្ចផ្តល់នូវភាពទន់ភ្លន់ខ្លះ ដោយសារទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា ត្រូវបានគិតជាមធ្យមក្នុងរយៈពេលតម្កល់។ ប៉ុន្តែ គ្រឹះស្ថានត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីធានាការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់អប្បបរមា ដូចបានកំណត់ក្នុងប្រការ ១៤ នៃប្រកាសនេះ។

មធ្យមភាគទ្រព្យសកម្មអប្បបរមាដែលត្រូវតម្កល់លើកលែងតែសមតុល្យគណនីផាត់ទាត់ត្រូវកំណត់តាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា នៅទូទាំងរយៈពេលត្រូវតម្កល់។ គ្រឹះស្ថានបានប្រតិបត្តិតាមប្រកាសនេះ ប្រសិនបើចំនួនមធ្យមភាគទ្រព្យសកម្មដែលអាចទទួលយកបានត្រូវបានរក្សានៅគ្រប់រយៈពេលតម្កល់យ៉ាងតិចបំផុតស្មើ ឬលើសពី ១០០% (មួយរយភាគរយ) នៃចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលបានគណនាដោយផ្អែកលើតួលេខនៅក្នុងរបាយការណ៍រយៈពេលមូលដ្ឋានពីមុនមក។

**ប្រការ ១២.-**

គណនីផាត់ទាត់ជាប្រាក់រៀលរបស់គ្រឹះស្ថានមានសមតុល្យវិជ្ជមាន ជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល។ សមតុល្យនេះនឹងត្រូវបានយកមកបូកបញ្ចូលគ្នារាល់ថ្ងៃ ហើយសមតុល្យសរុបនេះត្រូវបូកនិងសមតុល្យសរុបគណនីប្រាក់បម្រុងកាតព្វកិច្ចនៅចុងគ្រានៃរយៈពេលតម្កល់។ ផលចែករវាងចំនួនសរុបខាងលើជាមួយនឹង ១៤ ត្រូវបានយកមកប្រៀបធៀបជាមួយចំនួនប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវប្រតិបត្តិតាម។

**ប្រការ ១៣.-**

សមតុល្យគណនីផាត់ទាត់ជារូបិយប័ណ្ណ មិនមែនជាទ្រព្យសកម្មដែលអាចទទួលយកបាន សម្រាប់ប្រតិបត្តិតាមប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារូបិយប័ណ្ណទេ។

## ជំពូកទី ៦
## កម្រិតកំណត់អប្បបរមានៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ និងឱនភាពប្រាក់បម្រុងកាតព្វកិច្ច

**ប្រការ ១៤.-**

ទោះបីជាការគិតមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចក្នុងរយៈពេល ១៤ ថ្ងៃ អនុញ្ញាតឱ្យមានភាពទន់ភ្លន់ខ្លះ គ្រឹះស្ថានត្រូវរក្សាទុកជាអចិន្ត្រៃយ៍ក្នុងរយៈពេលតម្កល់១៤ថ្ងៃ នូវកម្រិតកំណត់កាតព្វកិច្ចអប្បបរមាប្រចាំថ្ងៃស្មើនឹង ៣០% ជាប្រាក់រៀល និង ៨០% ជារូបិយប័ណ្ណ នៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចដែលបានកំណត់ក្នុងរយៈពេលមូលដ្ឋាន។

គ្រឹះស្ថានត្រូវប្រតិបត្តិតាមប្រចាំថ្ងៃនូវកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៣០% ចំពោះប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និង ៨០% ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ នៅទូទាំងរយៈពេលតម្កល់ ដោយរក្សាឱ្យបានយ៉ាងតិចបំផុតនូវចំនួនសមតុល្យក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និងជារូបិយប័ណ្ណ នៅធនាគារជាតិនៃកម្ពុជា។

ទោះបីជាសមតុល្យគណនីផាត់ទាត់ជាទ្រព្យសកម្មដែលអាចទទួលយកបានជាប្រាក់រៀល ក៏គ្រឹះស្ថានមិនត្រូវបញ្ចូលសមតុល្យគណនីផាត់ទាត់នេះ ជាមួយសមតុល្យគណនីទ្រព្យសកម្មបម្រុង ដើម្បីឱ្យប្រតិបត្តិតាមកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៣០% ឡើយ។

**ប្រការ ១៥.-**

ការល្មើសនឹងកម្រិតកំណត់កាតព្វកិច្ចអប្បបរមាប្រចាំថ្ងៃស្មើនឹង ៣០% ជាប្រាក់រៀល និង ៨០% ជារូបិយប័ណ្ណ និងការរក្សាទុកមធ្យមភាគនៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាមិនគ្រប់គ្រាន់ក្នុងរយៈពេលតម្កល់ ត្រូវចាត់ទុកថាមានឱនភាពប្រាក់បម្រុងកាតព្វកិច្ច នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ និងវិធានការត្រួតពិនិត្យគ្រឹះស្ថានដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៧
## ការអនុវត្ត និងការរាយការណ៍ចំពោះការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា

**ប្រការ ១៦.-**

គ្រឹះស្ថានត្រូវអនុវត្តការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល និងរូបិយប័ណ្ណ ដូចមានណែនាំលម្អិតក្នុងបរិសិដ្ឋ ២ នៃប្រកាសនេះ។

**ប្រការ ១៧.-**

គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលមូលដ្ឋាន និងរបាយការណ៍រយៈពេលតម្កល់ដូចមានរៀបរាប់ខាងក្រោម៖

- របាយការណ៍រយៈពេលមូលដ្ឋាន៖ គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលមូលដ្ឋាន ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីចប់រយៈពេលមូលដ្ឋាន។ របាយការណ៍

នេះត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ច ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៣០% ចំពោះប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល និង ៨០% ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀលនិងរូបិយប័ណ្ណ។ តារាងរបាយការណ៍រយៈពេលមូលដ្ឋាន មានភ្ជាប់ក្នុងបរិសិដ្ឋ ១ នៃប្រកាសនេះ។

- របាយការណ៍រយៈពេលតម្កល់៖ គ្រឹះស្ថានត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជានូវរបាយការណ៍រយៈពេលតម្កល់ ក្នុងអំឡុងពេល ៣ (បី) ថ្ងៃ បន្ទាប់ពីចប់រយៈពេលតម្កល់។ របាយការណ៍នេះត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មដែលអាចទទួលយកបាននៅធនាគារជាតិនៃកម្ពុជា និងត្រូវរាយការណ៍ដាច់ដោយឡែកពីគ្នារវាងប្រាក់រៀល និងរូបិយប័ណ្ណ ហើយត្រូវបង្ហាញភស្តុតាងបញ្ជាក់ថាបានប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកម្រិតកំណត់កាតព្វកិច្ចអប្បបរមាប្រចាំថ្ងៃ ៣០% ជាប្រាក់រៀល និង ៨០% ជារូបិយប័ណ្ណ។ តារាងរបាយការណ៍រយៈពេលតម្កល់ មានភ្ជាប់ក្នុងបរិសិដ្ឋ ១ នៃប្រកាសនេះ។

## ជំពូកទី ៨
## ទណ្ឌកម្ម និងពិន័យ

**ប្រការ ១៨**.-

ករណីមិនអាចអនុវត្តបាននូវកម្រិតកំណត់កាតព្វកិច្ចអប្បបរមាប្រចាំថ្ងៃដែលស្មើនឹង ៣០% ជាប្រាក់រៀល និង ៨០% ជារូបិយប័ណ្ណ នៃប្រាក់បម្រុងកាតព្វកិច្ចដែលត្រូវតម្កល់ គ្រឹះស្ថានត្រូវរងការផាកពិន័យស្មើនឹង ២% នៃចំនួនឱនភាពនោះ (៣០% និង ៨០% នៃប្រាក់បម្រុងកាតព្វកិច្ចជារៀល និងរូបិយប័ណ្ណ ដកប្រាក់តម្កល់ក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច) ចំពោះឱនភាពលើកទី១ នៃរយៈពេលតម្កល់។ ក្នុងករណីមានឱនភាពម្តងហើយម្តងទៀតកើតឡើងនៅរយៈពេលតម្កល់បន្ទាប់គ្នា នោះការផាកពិន័យនឹងកើនដល់ ៤%។

**ប្រការ ១៩**.-

ករណីមានឱនភាពប្រាក់បម្រុងកាតព្វកិច្ច ដោយសារការតម្កល់មិនគ្រប់គ្រាន់នូវមធ្យមភាគនៃទ្រព្យសកម្មបម្រុងក្នុងរយៈពេលតម្កល់ គ្រឹះស្ថានត្រូវទទួលរងការផាកពិន័យស្មើនឹង ២% នៃចំនួនប្រាក់ឱនភាព ដែលបានមកពីភាពខុសគ្នារវាងចំនួននៃមធ្យមភាគប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាក្នុងរយៈពេលតម្កល់ និងមធ្យមភាគទ្រព្យសកម្មបម្រុងដែលបានតម្កល់។ ក្នុងករណីមានឱនភាពជាបន្តបន្ទាប់ នោះការផាកពិន័យនឹងត្រូវកើនឡើងដល់ ៤%។

**ប្រការ ២០**.-

ការល្មើសកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ និងឱនភាពនៃប្រាក់បម្រុងកាតព្វកិច្ច អាចបង្ហាញថា គ្រឹះស្ថានមានបញ្ហាក្នុងការគ្រប់គ្រងជាក់ស្តែង និង/ឬ បញ្ហាជាសក្តានុពលលើសន្ទនីយភាព។ ធនាគារជាតិនៃកម្ពុជា នឹងចាត់វិធានការត្រួតពិនិត្យដ៏សមស្របដើម្បីកែតម្រូវស្ថានភាពនេះ និងប្រើសិទ្ធិអំណាចដាក់ពិន័យ ដូចដែលមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

# ជំពូកទី ៩
# អវសានប្បញ្ញត្តិ

**ប្រការ ២១.-**

ប្រកាសលេខ ធ៧-០២៤-៣៣៦ ប្រ.ក ចុះថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ ស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២២.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកប្រតិបត្តិការ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៣.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៥

**ទេសាភិបាល**

ជា សិរី

**កន្លែងទទួល៖**
- ដូចប្រការ ២២ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

## បរិសិដ្ឋ ១
## របាយការណ៍ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា
## របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ១.- របាយការណ៍រយៈពេលមូលដ្ឋាន

របាយការណ៍នេះត្រូវលម្អិតអំពីសមតុល្យប្រាក់បញ្ញើ និងប្រាក់កម្ចីប្រចាំថ្ងៃទៅតាមប្រភេទរូបិយប័ណ្ណ នៅក្នុងរយៈពេលមូលដ្ឋាន ដែលបង្ហាញអំពីចំនួនប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាសម្រាប់រក្សាទុកនៅក្នុងរយៈពេលតម្កល់ ព្រមទាំងបង្ហាញពីកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៣០% ជាប្រាក់រៀល និង ៨០% ជារូបិយប័ណ្ណ។

គ្រឹះស្ថានត្រូវផ្តល់របាយការណ៍រយៈពេលមូលដ្ឋាននេះ មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣ (បី) ថ្ងៃ ចាប់ពីថ្ងៃចប់រយៈពេលមូលដ្ឋាន៖

- តារាង ១ក ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារៀល
- តារាង ១ខ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗ គិតជាដុល្លារអាមេរិក។ តារាងនេះប្រើសម្រាប់គណនាសង្ខេបតួលេខសរុបបញ្ចូលគ្នាតាមថ្ងៃ តាមប្រភេទរូបិយប័ណ្ណ សម្រាប់ទ្រព្យអកម្មដែលត្រូវយកមកគណនាប្រាក់បម្រុងកាតព្វកិច្ច។ របាយការណ៍សង្ខេបនេះនឹងត្រូវបានភ្ជាប់បន្ថែមដោយតារាងលម្អិតជាច្រើនទៀតតាមប្រភេទរូបិយប័ណ្ណដែលគ្រឹះស្ថានបានធ្វើប្រតិបត្តិការជាក់ស្តែង។
  - តារាង ១ខ-០១ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក
  - តារាង ១ខ-០២ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង ១ខ-០៣ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអូស្ត្រាលី គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង ១ខ-០៤ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង ១ខ-០៥ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាផោនអង់គ្លេស គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង ១ខ-០៦ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារសាំងហ្គាពួរ គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
  - តារាង ១ខ-០៧ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាយេនជប៉ុន គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា

- តារាង ១ខ-០៨ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារហុងកុង គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-០៩ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារកាណាដា គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១០ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាប៉េសូហ្វីលីពីន គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១១ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាវៀតណាមដុង គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១២ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាយ៉ន់ចិន គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១៣ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាមាស គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១៤ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាយ៉ន់ចិននៅហុងកុង គិតជាដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា
- តារាង ១ខ-១៥ ៖ របាយការណ៍រយៈពេលមូលដ្ឋានស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណផ្សេងទៀត គិតជាដុល្លារអាមេរិក ជាតារាងបន្ថែមចំពោះរូបិយប័ណ្ណផ្សេងៗដែលខុសពីរូបិយប័ណ្ណខាងលើទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន។

## ២.- របាយការណ៍រយៈពេលតម្កល់

របាយការណ៍នេះបង្ហាញពីសមតុល្យប្រចាំថ្ងៃនៃទ្រព្យសកម្មបម្រុង ដែលរក្សានៅធនាគារជាតិនៃកម្ពុជា និងឱនភាពកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃតាមរយៈការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចជាមធ្យមប្រចាំថ្ងៃ។

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍រយៈពេលតម្កល់នេះ មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣ ថ្ងៃ បន្ទាប់ពីថ្ងៃចប់រយៈពេលតម្កល់។

- តារាង ២ក ៖ របាយការណ៍រយៈពេលតម្កល់ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល។ របាយការណ៍នេះ ប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា និងកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ ៣០% ដែលទទួលបានពីតារាង ១ក។
- តារាង ២ខ ៖ របាយការណ៍រយៈពេលតម្កល់ស្តីពីប្រាក់បម្រុងកាតព្វកិច្ចគិតជាដុល្លារអាមេរិក។

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពី ប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀល
## Report of Base Period on Reserve Requirement in KHR

**ឈ្មោះគ្រឹះស្ថាន**/Name of Institution:
**រយៈពេលមូលដ្ឋាន**/Base Period:
**រយៈពេលតម្កល់**/Maintenance Period:
**រយៈពេលត្រូវរាយការណ៍**/Reporting Period:

តារាង : ១ក
Table: 1A

(គិតជាលានរៀល)
(In Million Riels)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជារៀល Deposits and other borrowings Base in KHR | | | | | |
|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | **សរុប Total** |
| | 1 | 2 | 3 | 4 | 5 | **6=1+2+3+4+5** |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| | | | | | | 0.00 |
| **សរុប** Total | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| **មធ្យមប្រចាំថ្ងៃ** Daily average | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | | | | | | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៧%) Reserve Requirement Rate (7%) | | | | | | 7.0% |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជារៀល** Minimum reserve requirements in KHR | | | | | | - |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៣០%) Daily compulsory threshold (30%) | | | | | | - |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
Reporting Date:

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Verified by | Prepared By |

# របាយការណ៍រយៈពេលមូលដ្ឋាន ស្ដីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក និងរូបិយប័ណ្ណផ្សេងៗ គិតជាដុល្លារអាមេរិក
## Report of Base Period on Reserve Requirement in USD and Other Currencies Converted into USD

**ឈ្មោះគ្រឹះស្ថាន**/Name of Institution: តារាង : ១ខ

**រយៈពេលមូលដ្ឋាន**/Base Period: Table: 1B

**រយៈពេលតម្កល់**/Maintenance Period: (គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period: (In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ជាដុល្លារអាមេរិក Deposits and other borrowings base in USD | ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ជាអឺរ៉ូ គិតជាដុល្លារអាមេរិក Deposits and other borrowings base in EUR Converted into USD | ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ជាថៃបាត គិតជាដុល្លារអាមេរិក Deposits and other borrowings base in THB Converted into USD | ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ ជា........ គិតជាដុល្លារអាមេរិក Deposits and other borrowings base in ... Converted into USD * | **សរុបប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗ គិតជាដុល្លារអាមេរិក Total Deposits and other borrowings Base Converted into USD** |
|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5=1+2+3+4 |
| | | | | | - |
| | | | | | - |
| | | | | | - |
| | | | | | - |
| | | | | | - |
| | | | | | - |
| | | | | | - |
| **សរុប** Total | - | - | - | - | - |
| **មធ្យមប្រចាំថ្ងៃ** Daily average | - | - | - | - | - |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា** (មធ្យមប្រចាំថ្ងៃ x ៧%) Minimum reserve requirement (Daily Average × 7%) | - | - | - | - | - |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | | | | | |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាដុល្លារអាមេរិក** (ទម្រង់ : ១ខ០១ + ១ខ០២ + ១ខ០៣ + ១ខ០៤ + ...+១ខ១៥) Minimum reserve requirements In USD (Form: 1B01+1B02+1B03+1B04+...+1B15) | | | | | $0.00 |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily Compulsory Threshold (80%) | | | | | - |

*** កំណត់សម្គាល់/Note:**

*កូឡោនច្រើនអាចត្រូវបានបន្ថែមសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

*There will be additional columns as needed for each of the Foreign Currencies transaction of the Institutions*

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Reporting Date:

| **នាយក** Manager | **អ្នកពិនិត្យ** Verified by | **អ្នកធ្វើតារាង** Prepared By |
|---|---|---|

# របាយការណ៍រយៈពេលមូលដ្ឋាន ស្ដីពីប្រាក់បម្រុងកាតព្វកិច្ចគិតជាដុល្លារអាមេរិក *
## Report of Base Period on Reserve Requirement in USD *

**ឈ្មោះគ្រឹះស្ថាន**/Name of Institution: តារាង : ១ខ-០១

**រយៈពេលមូលដ្ឋាន**/Base Period: Table: 1B-01

**រយៈពេលតម្កល់**/Maintenance Period: (គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period: (In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា..... Deposits and other borrowings base in ... | | | | | |
|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | **សរុប** Total |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| | | | | | | - |
| **សរុប** Total | - | - | - | - | - | - |
| **មធ្យមប្រចាំថ្ងៃ** Daily average | - | - | - | - | - | - |

| | |
|---|---|
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៧%) Reserve Requirement Rate (7%) | 7.0% |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា...... គិតជាដុល្លារអាមេរិក** Minimum reserve requirements converted into USD | **$0.00** |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | **$0.00** |

* **កំណត់សម្គាល់ / Note:**

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

*There will be additional tables as needed for each of the foreign currencies transaction of the Institutions*

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Reporting Date:

| **នាយក** | **អ្នកពិនិត្យ** | **អ្នកធ្វើតារាង** |
|---|---|---|
| Manager | Verified by | Prepared By |

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាថៃបាត គិតជាដុល្លារអាមេរិក *
## Report of Base Period on Reserve Requirement in THB Converted into USD*

**ឈ្មោះគ្រឹះស្ថាន**/Name of Institution:　　　　　　តារាង : ១ខ-០២

**រយៈពេលមូលដ្ឋាន**/Base Period:　　　　　　Table: 1B-02

**រយៈពេលតម្កល់**/Maintenance Period:　　　　　　(គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period:　　　　　　(In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា.... Deposits and other borrowings base in ... | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | សរុប Total | អត្រាប្តូរប្រាក់ប្រចាំថ្ងៃ .../ដុល្លារអាមេរិក Daily Exchange Rate .../USD | សរុបគិតជាដុល្លារអាមេរិក Total Converted into USD |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | 8=6/7 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| សរុប Total | - | - | - | - | - | - | | $0.00 |
| មធ្យមប្រចាំថ្ងៃ Daily average | - | - | - | - | - | - | | $0.00 |

| ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់ Reserve Requirement for maintenance period: | |
|---|---|
| អត្រាប្រាក់បម្រុងកាតព្វកិច្ច (៧%) Reserve Requirement Rate (7%) | 7.0% |
| ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា...... គិតជាដុល្លារអាមេរិក Minimum reserve requirements converted into USD | $0.00 |
| កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ (៨០%) Daily compulsory threshold (80%) | $0.00 |

*** កំណត់សម្គាល់ / Note:**

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

*There will be additional tables as needed for each of the foreign currencies transaction of the Institutions*

រាជធានីភ្នំពេញ ថ្ងៃទី　　ខែ　　ឆ្នាំ

Reporting Date:

| នាយក | អ្នកពិនិត្យ | អ្នកធ្វើតារាង |
|---|---|---|
| Manager | Verified by | Prepared By |

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអូស្ត្រាលី គិតជាដុល្លារអាមេរិក *
## Report of Base Period on Reserve Requirement in AUD Converted into USD *

**ឈ្មោះគ្រឹះស្ថាន**/Name of Institution: តារាង : ១ខ-០៣

**រយៈពេលមូលដ្ឋាន**/Base Period: Table: 1B-03

**រយៈពេលតម្កល់**/Maintenance Period: (គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period: (In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា..... Deposits and other borrowings base in ... | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | សរុប Total | អត្រាប្តូរប្រចាំថ្ងៃ .../ដុល្លារអូស្ត្រាលី Daily Exchange Rate .../AUD | សរុបគិតជាដុល្លារអាមេរិក Total Converted into USD |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | 8=6/7 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | | | $0.00 |
| | | | | | | | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| **សរុប** Total | - | - | - | - | - | - | | $0.00 |
| **មធ្យមប្រចាំថ្ងៃ** Daily average | - | - | - | - | - | - | | $0.00 |

| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | |
|---|---|
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៧%) Reserve Requirement Rate (7%) | 7.0% |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា...... គិតជាដុល្លារអាមេរិក** Minimum reserve requirements converted into USD | $0.00 |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | $0.00 |

*** <u>កំណត់សម្គាល់ / Note:</u>**

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

*There will be additional tables as needed for each of the foreign currencies transaction of the Institutions*

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Reporting Date:

| **នាយក** Manager | **អ្នកពិនិត្យ** Verified by | **អ្នកធ្វើតារាង** Prepared By |
|---|---|---|

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជាអឺរ៉ូ គិតជាដុល្លារអាមេរិក *

## Report of Base Period on Reserve Requirement in EUR Converted into USD *

**ឈ្មោះគ្រឹះស្ថាន**/Name of Institution: តារាង : ១ខ-០៤

**រយៈពេលមូលដ្ឋាន**/Base Period: Table: 1B-04

**រយៈពេលតម្កល់**/Maintenance Period: (គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period: (In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | **ប្រាក់បញ្ញើនិងប្រាក់កម្ចីផ្សេងៗជា....** Deposits and other borrowings base in ... | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | **សរុប** Total | អត្រាប្តូរប្រចាំថ្ងៃ .../អឺរ៉ូ Daily Exchange Rate .../EUR | **សរុបគិតជាដុល្លារអាមេរិក Total Converted into USD** |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | 8=6/7 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| **សរុប** Total | - | - | - | - | - | - | | $0.00 |
| **មធ្យមប្រចាំថ្ងៃ** Daily average | - | - | - | - | - | - | | $0.00 |

| | |
|---|---|
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៧%) Reserve Requirement Rate (7%) | 7.0% |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា...... គិតជាដុល្លារអាមេរិក** Minimum reserve requirements converted into USD | $0.00 |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | $0.00 |

*** កំណត់សម្គាល់ / Note:**

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

*There will be additional tables as needed for each of the foreign currencies transaction of the Institutions*

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

Reporting Date:

| **នាយក** Manager | **អ្នកពិនិត្យ** Verified by | **អ្នកធ្វើតារាង** Prepared By |
|---|---|---|

# របាយការណ៍រយៈពេលមូលដ្ឋាន ស្តីពីប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណផោនអង់គ្លេស គិតជាដុល្លារអាមេរិក *
## Report of Base Period on Reserve Requirement in GBP Converted into USD *

**ឈ្មោះគ្រឹះស្ថាន**/Name of Institution: តារាង : ១ខ-០៥

**រយៈពេលមូលដ្ឋាន**/Base Period: Table: 1B-05

**រយៈពេលតម្កល់**/Maintenance Period: (គិតជាដុល្លារអាមេរិក)

**រយៈពេលត្រូវរាយការណ៍**/Reporting Period: (In USD)

| កាលបរិច្ឆេទនៃរយៈពេលមូលដ្ឋាន Date of Base Period | ប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗជា.... Deposits and other borrowings base in ... | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រាក់បញ្ញើចរន្ត Demand Deposit | ប្រាក់បញ្ញើសំចៃ Saving Deposit | ប្រាក់បញ្ញើមានកាលកំណត់ Term Deposit | ប្រាក់បញ្ញើផ្សេងៗ Other Deposits | បំណុលផ្សេងទៀត Other Liabilities | សរុប Total | អត្រាប្តូរប្រចាំថ្ងៃ .../ផោនអង់គ្លេស Daily Exchange Rate .../GBP | សរុបគិតជាដុល្លារអាមេរិក Total Converted into USD |
| | 1 | 2 | 3 | 4 | 5 | 6=1+2+3+4+5 | 7 | 8=6/7 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| | | | | | | - | | $0.00 |
| **សរុប** Total | - | - | - | - | - | - | | $0.00 |
| **មធ្យមប្រចាំថ្ងៃ** Daily average | - | - | - | - | - | - | | $0.00 |
| **ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់តម្កល់ក្នុងរយៈពេលត្រូវតម្កល់** Reserve Requirement for maintenance period: | | | | | | | | |
| **អត្រាប្រាក់បម្រុងកាតព្វកិច្ច** (៧%) Reserve Requirement Rate (7%) | | | | | | | | 7.0% |
| **ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជា...... គិតជាដុល្លារអាមេរិក** Minimum reserve requirements converted into USD | | | | | | | | $0.00 |
| **កម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃ** (៨០%) Daily compulsory threshold (80%) | | | | | | | | $0.00 |

*** កំណត់សម្គាល់ / Note:**

*តារាងច្រើនអាចត្រូវបង្កើតសម្រាប់រូបិយប័ណ្ណផ្សេងៗទៀតទៅតាមប្រតិបត្តិការរបស់គ្រឹះស្ថាន*

